# ភ្នំពេញ - ព្រះសីហនុ - កំពត (៣ថ្ងៃ២យប់)

## ថ្ងៃទី១ : ភ្នំពេញ_ខេត្តព្រះសីហនុ_ឆ្នេរអូរឈើទាល_រមណីយដ្ឋានក្បាលឆាយ(អាហារ ៣ពេល)



ម៉ោង៦:០០ធ្វើដំណើរពីភ្នំពេញឆ្ពោះទៅខេត្តព្រះសីហនុតាមផ្លូវជាតិលេខ៤។ គយគន់ទេសភាពព្រៃព្រឹក្សាខៀវស្រងាត់នៅតាមដងផ្លូវពេល ទៅដល់ទស្សនាផ្សារលើ រង្វង់មូលរូបសំណាក់សត្វតោមាសញីឈ្មោលនិងទទួលទានអាហារថ្ងៃត្រង់នៅមុខឆ្នេរអូរឈើទាលជាមួយមុខម្ហូបសមុទ្រ ដ៏ឆ្ងាញ់ពិសារ ហើយងូតទឹកលេង និងជិះផ្លៃចេក នៅលើសមុទ្រ បន្ទាប់ មកជូនទៅទស្សនានៅរមណីយដ្ឋានក្បាលឆាយហើយត្រលប់មកទទួលទានអាហារពេលល្ងាចនៅភោជណីយដ្ឋាន និងជូនទៅសណ្ឋារគារ។ ជិះផ្លៃចេកចំណាយផ្ទាល់ខ្លួន។

## ថ្ងៃទី២ : កោះឫស្សី_កំពង់ផែអន្តរជាតិ_ខេត្តកំពត_ កោះទន្សាយ (អាហារ ៣ពេល)



ពេលព្រឹកធ្វើដំណើរទៅទស្សនាកោះឫស្សីដែលជាកោះមួយពេញនិយមនៅខេត្តព្រះសីហនុ ដើម្បីទស្សនាទេសភាព ដ៏ស្រស់ត្រកាលនៃផ្កាថ្មនិងសម្រស់ធម្មជាតិនៅលើកោះឫស្សីនិងទទួលទានអាហារថ្ងៃត្រង់នៅលើកោះយ៉ាងឆ្ងាញ់ពិសារហើយត្រលប់ទៅទស្សនាកំពង់ផែអន្តរជាតិ និងបន្ត ដំណើរទៅខេត្តកំពត ដើម្បីទស្សនាកំសាន្តនៅ កោះទន្សាយដែលជាកោះ មួយមានការទាក់ទាញ និងចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ទេសចរជាតិ និងអន្តរជាតិបន្ទាប់មកទទួលទានអាហារពេលល្ងាចជាមួយមុខម្ហូបសមុទ្រដ៏ឆ្ងាញ់ពិសារនិងស្តាប់សំឡេងទឹករលកសមុទ្រនារាត្រីដ៏ស្រស់ត្រកាលនៅលើកោះទន្សាយ។

## ថ្ងៃទី៣ : កំពត_ភ្នំពេញ (អាហារ ២ពេល)



អាហារពេលព្រឹក រួចចូលទស្សនាផ្សារកំពតរួចធ្វើដំណើរត្រលប់មកភ្នំពេញវិញ និងទស្សនាទិដ្ឋភាពធម្មជាតិតាមដងផ្លូវពោរពេញដោយក្តីសប្បាយរីករាយរួមជាមួយមគ្គុទេសក៍ប៉ិនប្រសព្វប្រកបដោយភាពកក់ក្តៅនិងសុវត្ថិភាព។

**ដំណើរកំសាន្តរួមមាន :**

☞មធ្យោបាយធ្វើដំណើរដោយរថយន្តទេសចរណ៍ទំនើបមានម៉ាស៊ីនត្រជាក់
☞បន្ទប់ស្នាក់នៅរួមសំរាប់គ្នា ២នាក់ក្នុងមួយបន្ទប់ ៕ សណ្ឋាគារផ្កាយ
☞សំបុត្រចូលទស្សនា
☞អាហារតាមកម្មវិធី១ថ្ងៃ៣ពេលនិងទឹកបរិសុទ្ធ
☞សេវាកម្មពីមគ្គុទ្ទេសក៍ទេសចរណ៍
☞វត្ថុអនុស្សាវរីយ៍ពី ក្រុមហ៊ុន អេស៊ាអិចផ្លរ៉ឺទេសចរណ

**បញ្ជាក់:**

☞ចេញដំណើររាល់ថ្ងៃសុក្រ និងថ្ងៃបុណ្យជាតិផ្សេង និងទៅតាមតំរូវការចំពោះក្រុមដែលមានគ្នា ចាប់ពី១០នាក់ឡើង។
☞ក្មេងក្រោមអាយុ១២ឆ្នាំ ស្នាក់នៅជាមួយឪពុកម្តាយតំលៃ ៧៥% នៃមនុស្សពេញវ័យ
☞សំរាប់ការស្នាក់នៅបន្ទប់មួយម្នាក់ឯងត្រូវបង់បន្ថែម ១៥ ដុល្លារអាមេរិក
☞សូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់

**ព័ត៌មានលំអិតសូមអញ្ជើញទំនាក់ទំនង**

ទូរស័ព្ទលេខ: ០២៣ ២១៨ ៦០៩
អ៊ីមែល: book@asiaexplorertravel.com